គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee For Free And Fair Elections In Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក **ធុន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គលេខាធិការ
និង នាយក CCPCR

កញ្ញា **ស៊ុន ចាន់សែន**
Miss. SUN Chansen
ប្រធាន KYA

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

លោកស្រី **ពឹង យក់ហៀប**
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា **សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany
នាយិកា CWCC

លោក **គីម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

លោក **អាង ច័ន្ទឫទ្ធិ**
Mr. ANG Chanrith
នាយក KKKHRO

លោក **យង់ គិមអេង**
Mr. YONG Kim Eng
នាយក PDP-Center

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith

លោក **សឺន សែត**
Mr. SEN Set

ស.ប្រ.ក.៣/លេខ ១៥/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្ត កំពង់ឆ្នាំង

*ភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ១០០នាក់ មកពីគ្រប់ស្រុក និងក្រុង ក្នុងខេត្តកំពង់ឆ្នាំង និងមានសិក្ខាកាមស្ត្រីចូលរួម ប្រមាណ ៤០% បានជួបជុំគ្នានៅក្នុងសិក្ខាសាលា ម្ចាស់ឆ្នោតក្នុងការកំណត់ លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ឆ្នាំង ដើម្បីពិភាក្សា និងកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០៩។

អភិបាលរងខេត្តកំពង់ឆ្នាំង លោក សៀត គឹមលៀង បានថ្លែងបើកសិក្ខាសាលាថា ប្រជាពលរដ្ឋបាននឹងកំពុងអនុវត្តន៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ បន្តពីយុទ្ធសាស្ត្រចតុកោណដំណាក់ កាលទី ១ និងតាមរយៈសិក្ខាសាលានេះ អ្វីដែលប្រជាពលរដ្ឋលើកឡើង នឹងដាក់ជូនតំណាងរាស្ត្រ ព្រមទាំង ក្រុមប្រឹក្សាខេត្តយកទៅអនុវត្តន៍ ហើយលោកក៏មានការជឿជាក់ថា វិស័យអាទិភាពដែលប្រជាពលរដ្ឋបានលើកឡើងនឹងមានការពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្រចតុកោណ ដែលបានគ្របដណ្តប់ស្ទើរគ្រប់វិស័យទូទាំងប្រទេស។ ជាចុងក្រោយលោកក៏បានផ្តល់អានុសាសន៍ដល់ប្រជាពលរដ្ឋនៅក្នុងខេត្តកំពង់ឆ្នាំង អោយពិភាក្សាដោយគិតទៅលើភាពជាក់ស្តែងដែលមាននៅក្នុងខេត្តកំពង់ឆ្នាំង ។

អ្នកតំណាងរាស្ត្រ **ឃី វណ្ណដេត** មណ្ឌលកំពង់ឆ្នាំង និងសមាជិកក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង ឯកឧត្តម **ឡុង ឈុនឡៃ** មកពីគណបក្សប្រជាជនកម្ពុជា ឯកឧត្តម **ទឹម ប៊ុណ្ណា** មកពីគណបក្សសមរង្ស៊ី ឯកឧត្តម **ទាំ សារី** មកពីគណបក្សនរោត្តមរណឫទ្ធិ ដែលបានទទួលលទ្ធផលនៃវិស័យអាទិភាពទាំង១០ដោយផ្ទាល់ដៃទទួលស្គាល់ និងគាំទ្រព្រមទាំងឯកភាពទៅលើអ្វីដែលប្រជាពលរដ្ឋលើកឡើង ហើយបានសន្យាថានឹងដាក់ជូនរាជរដ្ឋាភិបាល និងគណៈអភិបាលខេត្តដើម្បីអនុវត្តលក្ខខណសន្ទស្សន៍នៃវិស័យអាទិភាពទាំងនេះ។

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង **ឃី វណ្ណដេត** បានមានប្រសាសន៍ថា *"សិក្ខាកាមខិតខំប្រឹងប្រែងដែលចេញជាលទ្ធផលនេះ,...ពិតជាសំណូមពរដែលប្រជាពលរដ្ឋទាមទារអោយរដ្ឋាភិបាលបំពេញ ហើយគួរតែចាប់អនុវត្តតាំងពីពេលនេះតទៅ,..ហើយក្នុងនាមខ្ញុំជាតំណាងរាស្ត្រខ្ញុំនឹងទទួលយកនូវសំណូមពរទាំង១០ និងជំរុញទៅរដ្ឋាភិបាលថ្នាក់ជាតិ និង ក្រោមជាតិដើម្បីជួយដោះស្រាយ "*។

ឯកឧត្តម **ឡុង ឈុនឡៃ** បានលើកឡើងថា *" [ខ្ញុំ ឯកភាពនិងគាំទ្រទទួលយកលក្ខខណ្ឌទាំង១០នេះ,... និងសំណូមពរអោយមានការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទាំងអស់ ហើយប្រជាពលរដ្ឋគួរចូលរួមអោយបានកុះករចំពោះការអនុវត្តនូវចំនុចទាំង នេះ "* ។

ឯកឧត្តម **ទាំ សារី** និងឯកឧត្តម **ទឹម ប៊ុណ្ណា** បានថ្លែងថា*" នឹងយក [លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ឆ្នាំង] ទៅដាក់ក្នុងរបៀបវារៈប្រជុំក្រុមប្រឹក្សាខេត្តដើម្បីធ្វើការអនុម័តដើម្បីអនុវត្តនូវចំនុចទាំងនេះ"*។

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តកំពង់ឆ្នាំងរួមមានៈ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង១០នៅក្នុងខេត្ត កំពង់ឆ្នាំង** |
|---|
| ១) សូមឱ្យរដ្ឋាភិបាលទប់ស្កាត់បទល្មើសនេសាទ និងការកាប់ព្រៃឈើឱ្យបាន ១០០% ក្នុងខេត្តកំពង់ឆ្នាំង ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ២) សូមឱ្យរដ្ឋាភិបាលផ្តល់ដីសម្បទានសង្គមកិច្ចសំរាប់ការដាំដំណាំដល់គ្រប់គ្រួសារប្រជាពលរដ្ឋក្រីក្រដែលខ្វះខាតដីក្នុងខេត្តកំពង់ឆ្នាំង ឱ្យបានត្រឹមឆ្នាំ ២០១០។ |
| ៣) ត្រូវមានការដេញថ្លៃជាសាធារណៈចំពោះការផ្គត់ផ្គង់ថាមពលអគ្គិសនីសម្រាប់ទូទាំងខេត្តកំពង់ឆ្នាំងចាប់ពីឆ្នាំ ២០១១ និងបញ្ចុះតំលៃអគ្គិសនី មកត្រឹម ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង អោយបានចាប់ពីឆ្នាំ ២០១០តទៅ។ |
| ៤) រដ្ឋាភិបាលត្រូវចេញច្បាប់ប្រឆាំងអំពើពុករលួយអោយចេញនៅដើមឆ្នាំ ២០១០។ |
| ៥) សូមជួយជំរុញការដោះស្រាយទំនាស់ដីធ្លី ដោយចេញប្លង់កម្មសិទ្ធិឱ្យបានគ្រប់ៗគ្នាទូទាំងខេត្តកំពង់ ឆ្នាំង យ៉ាងយូត្រឹមឆ្នាំ ២០១៣។ |
| ៦) សូមផ្តល់វគ្គបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មដល់ប្រជាកសិករក្នុងខេត្តឱ្យបាន ១០វគ្គ ក្នុងមួយឆ្នាំអោយ បានគ្រប់ភូមិ ក្នុងខេត្តកំពង់ឆ្នាំង ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៧)សូមឱ្យរដ្ឋាភិបាលជួយធ្វើអន្តរាគមន៍ដល់វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងខេត្តកំពង់ឆ្នាំង បញ្ចុះតំលៃអត្រាការប្រាក់ មកនៅត្រឹមតែ ១.៥ %/ ខែ ដើម្បីជួយសំរួលប្រជាពល រដ្ឋក្រីក្រចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៨) សូមឱ្យរដ្ឋាភិបាលជួយធ្វើបទអន្តរាគមន៍ដល់រោងចក្រនានានៅក្នុងខេត្ត កំពង់ឆ្នាំង ដោយតម្លើងប្រាក់ខែ ដល់កម្មករឱ្យបានសមស្របទៅនឹងតម្រូវ ការទីផ្សារ យ៉ាងហោចណាស់ចាប់ពី ៧០ដុល្លារ/ខែ ( ប្រាក់ខែគោល) ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៩) បញ្ចុះតំលៃសុខភាពអោយទាប ឬមិនគិតថ្លៃសំរាប់អ្នកក្រ អោយបាន៨០ភាគរយនៃតម្លៃបច្ចុប្បន្ន នៅតាមគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យ បង្អែកអោយបាននៅឆ្នាំ ២០១០ តទៅ។ |
| ១០) រដ្ឋាភិបាលត្រូវបង្កើតលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាអោយចេញនៅពាក់កណ្តាលឆ្នាំ ២០១០។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយ**គណៈកម្មាធិការខុមហ្វ្រែល** សហការជាមួយ**សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម សមាគមអភិវឌ្ឍន៍កុមារយុវជន សមាគមភ្នំនាងកង្រី និងអង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ** ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោតដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ មកពីស្រុកសាមគ្គីមានជ័យ ស្រុកទឹកផុស ស្រុកបរិបូរណ៍ ស្រុកជល់គីរី ស្រុកកំពង់ត្រឡាច ស្រុករលាប្អៀរ ស្រុកកំពង់លែង និងក្រុងកំពង់ឆ្នាំង នៅក្នុងខេត្តកំពង់ឆ្នាំង ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ចំនួ ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិនុឡ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦